# សេចក្តីណែនាំ នៃកម្មវិធីអនុវត្តច្បាប់

apogee
enterprises, inc.

គណៈកម្មការអនុវត្តច្បាប់ មេសា 2010
Russ Huffer • Jim Porter • Pat Beithon • Warren Planitzer • Greg Silvestri

ពេលដែលសេដ្ឋកិច្ច ប្រឆាំងនឹង លទ្ធភាពរបស់យើង ក្នុងការប្រព្រឹត្តិឱ្យបានល្អប្រសើរ វាជារឿងសំខាន់ ដែលយើងត្រូវធ្វើតាម ការប្តេជ្ញាចិត្តដ៏ខ្លាំងរបស់យើង ចំពោះអាកប្បកិរិយាបែអភិសមារចារ ។ លើសពីនេះទៅទៀត រដ្ឋាភិបាលសហព័ន្ធ ថ្នាក់រដ្ឋ និងប្រទេសបរទេស ដែលក្រុមហ៊ុន Apogee ធ្វើអាជីវកម្ម ព្រមទាំង មជ្ឈដ្ឋានសាធារណៈ កំពុងតែ តម្រូវឱ្យក្រុមហ៊ុនទាំងឡាយធ្វើការឃ្លាំពិនិត្យសកម្មភាពរបស់ខ្លួន ដើម្បីធានាឱ្យមានការអនុលោមច្បាប់និង វិន័យ ដែលមានចែងជាធរមាន ។ ដើម្បីជួយនិយោជិតឱ្យយល់នូវអ្វីដែលខ្លួនត្រូវធ្វើនិងប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវរបស់ខ្លួននោះ ក្រុមហ៊ុនបានបង្កើតឱ្យមានកម្មវិធីប្រតិបត្តិទូទាំងក្រុមហ៊ុនមួយដែលមានបញ្ចូលគោលការណ៍ណែនាំនេះ ក្រឹត្យក្រម ប្រតិបត្តិ និងធ្វើអាជីវកម្មដែលគួសបញ្ជាក់នូវគោលការណ៍និងបទដ្ឋានសីលធមិណែនាំសំរាប់ការធ្វើអាជីវកម្មរបស់ខ្លួន ច្បាប់សាជីវកម្ម ដែលបង្កើតឡើងឱ្យមានច្បាប់ប្រតិបត្តិជាក់លាក់ ដែលនិយោជិតត្រូវតែគោរពជាដាច់ខាត ។

និយោជិតទាំងអស់ និង សមាជិកក្រុមនាយក ត្រូវតែទទួលខុសត្រូវក្នុងការគោរពអនុវត្តតាមច្បាប់ បទដ្ឋាន និងគោលការណ៍ទាំងឡាយដែលមានចែង នៅក្នុងកម្មវិធីនៃការអនុវត្តន៏ច្បាប់របស់ក្រុមហ៊ុន Apogee ក្រមសីលធមិជំនួញ និងរបៀបរបបជំនួញ, និងគោលនយោបាយស្ទួលនានា ។ គោលនយោបាយស្ទួលនឹងត្រូវយកទៅអនុវត្តលើគ្រប់និយោជិតទាំងអស់របស់ក្រុមហ៊ុន និងនាយកនៅក្នុងនោះមាននិយោជិតក្រុមហ៊ុន Apogee និងនិយោជិតនៅតាមសាខា ផ្នែកក្រុមទីផ្សារ និងតាមក្រុមជំនួញនានារបស់ក្រុមហ៊ុន Apogee នានា លើកលែងតែនៅក្នុងវិសាលភាពណាដែលគោលនយោបាយស្ទួលទាំងនេះផ្ទុយពីកិច្ចព្រមព្រៀងនៃការចរចារគ្នារួមណាមួយ ដែលនៅជាធរមាន រឺកាតព្វកិច្ចដទៃទៀតរបស់ ក្រុមហ៊ុននៅក្រោមច្បាប់សហព័ន្ធ រដ្ឋ រឺច្បាប់ក្នុងស្រុក ។

ការរំលោភបំពានលើច្បាប់ លើកម្មវិធីអនុវត្តច្បាប់ រឺលើគោលនយោបាយស្ទួល និតិវិធី ការណែនាំ វិន័យការងារ ទំនៀមទំលាប់ រឺទៅលើអ្វីដទៃទៀតដូចគ្នានេះនឹងអាចទទួលនូវពិន័យរដ្ឋបាលដែលមានរួមទាំងការបណ្តេញចេញផងដែរ ។ បន្ថែមលើនេះក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការប្តឹងនិយោជិតក្នុងបទរដ្ឋប្បវេណីក្នុងករណីដែលមានការរំលោភបំពានធ្ងន់ធ្ងរណាមួយហើយ បញ្ជូនករណីនោះទៅអាជ្ញាធរច្បាប់ រឺអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការដោះស្រាយ ។ គ្មានអ្វីនៅក្នុងសេចក្តីណែនាំនេះ ក្រមសីលធមិជំនួញ និងរបៀបរបបជំនួញ គោលនយោបាយស្ទួល រឺការប្រស្រ័យនៃកម្មវិធីអនុវតតច្បាប់នានាបង្កើតអោយ មាន រឺ កំណត់ជាកិច្ចសន្យាការងារឡើយ ។

ដើម្បីជួយនិយោជិតក្នុងការយល់ពីច្បាប់និងបញ្ញតិទាំងឡាយដែលមានផលប៉ះពាល់ដល់ក្រុមហ៊ុន សេចក្តីសង្ខេបស្តីពីគោលនយោបាយស្ទួលខាងក្រោមនេះត្រូវបានបង្កើតឡើង ។ និយោជិតទាំងអស់ត្រូវតែយល់ដឹងអោយបានច្បាស់ពីច្បាប់ និងបញ្ញតិទាំងឡាយណាដែលមានការទាក់ទងទៅនឹងការងាររបស់ខ្លួន ។ ឯកសារស្តីពីក្រុមសីលធមិជំនួញ និងរបៀបរបបជំនួញ គោល នយោបាយស្ទួល និងគោលនយោបាយដទៃទៀតរបស់ក្រុមហ៊ុន Apogee គឺមានដាក់អោយនិយោជិតសំរាប់ពិនិត្យស្វែង យល់ ។ និយោជិតទាំងឡាយអាចសាកសួរសំណួរស្តីអំពីការបកស្រាយក្រឹតក្រមប្រតិបត្តិនិងធ្វើអាជីវកម្ម ឬក៏ច្បាប់ សាជីវកម្មជាក់លាក់ ឬក៏ច្បាប់ក្រុមហ៊ុនដទៃទៀត ដោយទាក់ទងអ្នកច្បាប់របស់ក្រុមហ៊ុន Apogee នៅឯការិយាល័យ សាជីវកម្មរបស់ Apogee តាមរយៈលេខ 952-487-7514 ឬដោយការទាក់ទងបណ្តាញ Hotline ផ្នែកក្រឹត្យក្រម ប្រតិបត្តិរបស់ Apogee តាមរយៈលេខ 1-800-441-6164 ឬ www.guideline.lrn.com (សូមដាក់បញ្ចូលឈ្មោះ ស្ថាប័ន Apogee) ។

តទៅនេះគឺជាសេចក្តីសង្ខេបដែលគេរៀបរៀងឡើងដើម្បីជួយលោកអ្នកក្នុងការស្វែងយល់គោលនយោបាយស្ទួលនៃកម្មវិធីអនុវត្តច្បាប់ ។ ស្ថានភាពណាមួយដែលមិនមាននិយាយនៅក្នុងសេចក្តីសង្ខេបនេះអាច រឺមិនអាចទទួលយកបាន ។ ប្រសិនជាលោកអ្នកមានសំណួរអ្វីមួយសូមទាក់ទងអ្នកគ្រប់គ្រងរបស់លោកអ្នក នាយកដ្ឋានបុគ្គលិក មេធាវីក្រុមហ៊ុន Apogee រឺក៏សមាជិកណាម្នាក់នៃគណកម្មការត្រួតពិនិត្យការអនុវត្តច្បាប់ក្រុមហ៊ុន Apogee ។

សូមចងចាំថាក្រុមហ៊ុន Apogee គឺពឹងផ្អែកទៅលើលោកអ្នកក្នុងការជួយជំរុញអោយសេចក្តីប្តេជ្ញាក្នុងការអនុវត្តច្បាប់របស់ក្រុមហ៊ុនទទួលបានលទ្ធផលសមស្របទៅតាមគោលការណសីលធមិ ច្បាប់ ព្រមទាំងរបៀបរបបគណនេយ្យនិងសាវនកម្ម សមរម្យទាំងឡាយរបស់ក្រុមហ៊ុន ។

## ការរាយការណ៍ និងការស៊ើបអង្កេតការរំលោភបំពាន

បើសិនជាអ្នកមានជំនឿថា ជនណាម្នាក់ប្រហែល ជាបានបំពានច្បាប់គោលការណ៏ ឬក៏បទដ្ឋានទាំងឡាយដែលមានចែងនៅ ក្នុងគោលការណ៍ណែនាំនេះ ក្រឹត្យក្រម ប្រតិបត្តិនិងអាជីវកម្ម ឬក៏អ្នកមានការបារម្ភស្តីអំពីការរៀបចំ បញ្ជីគណនេយ្យ ឬក៏ការឆែកពិនិត្យ កិច្ចការគណនេយ្យមិនច្បាស់លាស់ អ្នកគួរធ្វើសេចក្តីរាយការណ៏ស្តីអំពីការបំពានដែល គេដឹងឮ ឬក៏អ្វីដែលគេសង្ស័យថាជាការបំពាន ឬក៏ការបារម្ភរបស់អ្នកនោះ ។ អ្នកអាចធ្វើសេចក្តីរាយការណ៍អំពីការបំពានណាមួយ ឬក៏ការបារម្ភរបស់អ្នក ទៅកាន់អ្នកមើលការខុសត្រូវផ្ទាល់របស់អ្នក អ្នកចាត់ចែងជាន់ខ្ពស់ណាម្នាក់ នាយកដ្ឋានធនធានមនុស្សរបស់អ្នក និងអ្នកច្បាប់របស់ក្រុមហ៊ុន Apogee តាមទូរស័ព្ទលេខ 952-478-7514 ឬក៏សមាជិកណាម្នាក់របស់គណៈកម្មាធិការប្រតិបតិតរបស់ក្រុមហ៊ុន Apogee តាមរយៈលេខទូរស័ព្ទលេខ 952-835-1874 ឬក៏ដោយការសរសេរលិខិតទៅកាន់ក្រុមហ៊ុន Apogee តាមរយៈលេខ 7900 Xerxes Avenue South, Suite 1800, Minneapolis, Minnesota 55431-1159 អ្នកក៏អាចធ្វើសេចក្តីរាយការណ៏ដោយរក្សាភាព អនាមិកបានដែរដោយទាក់ទងបណ្តាញ Hotline ផ្នែកក្រឹត្យក្រមប្រតិបត្តិរបស់ Apogee តាមរយៈលេខ 1-800-441-6164 ឬ www.guideline.lrn.com (សូមដាក់បញ្ចូលឈ្មោះស្ថាប័ន Apogee) ។ ទូរស័ព្ទ ខ្សែតលិនៃ ផ្នែកក្រឹត្យក្រមប្រតិបត្តិរបស់ Apogee គ្រប់គ្រងដោយក្រុមហ៊ុនមួយផ្សេងទៀត ដែលពុំមានការទាក់ទងនឹងក្រុមហ៊ុន Apogee ឡើយ ។

របាយការណ៍នីមួយ អំពីការរំលោភលើច្បាប់ ឬកម្មវិធីអនុវត្តច្បាប់ ឬកំហុសផ្នែកគណនេយ្យ ឬសវនកម្មដែលអាចសួរបាន ដោយមានការដឹងឮ ឬមានការសង្ស័យ នឹងត្រូវចុះអង្កេតឱ្យបានលឿន និងដោយហ្មត់ចត់ ។ បើការរំលោភណាមួយបានកើតឡើង ក្រុមហ៊ុន Apogee នឹងអនុវត្តសកម្មភាពទទួលខុសត្រូវ ដើម្បីការពារ កុំឱ្យមានការរំលោភស្រដៀងគ្នានេះ ទៅថ្ងៃមុខ ។

ទូរស័ព្ទ HOTLINE ផ្នែកក្រឹត្យក្រម
ប្រតិបត្តិរបស់ APOGEE
1-800-441-6164 or www.guideline.lrn.com
(សូមដាក់បញ្ចូលឈ្មោះស្ថាប័ន Apogee)